# ការសំភាសន៍របស់អ៊ុំស្រី ពេជ្រ វី

កះ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ារ ខះ អ្នកដែរអោយគេសំភាសន៍ ពេជ្រ វី

## ការសង្ខេបប្រវត្តិរបស់ អ៊ុំស្រី ពេជ្រ វី

អ៊ុំស្រី ពេជ្រ វី មានអាយុ62 នៅក្នុងឆ្នាំ2018 អ៊ុំស្រី ពេជ្រ វី មានភេទស្រី អ៊ុំស្រី ពេជ្រ វី មានទីលំនៅបច្ចុប្បន្ននៅភូមិស្ទឹងជ្រៅ ឃុំផ្សារដើមមាន ស្រុកតាខ្មៅ ខេត្តកណ្ដាល។

កះ ចឹងជាដំបូងខ្ញុំអរគុណអ៊ុំដែរបានអោយខ្ញុំពិភាក្សាពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីអោយកូនចៅជំនាន់ក្រោយៗដើម្បីទុកអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយនឹង ប្រវត្តិរបស់ដូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍អ៊ុំ ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់អ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខះ ចាំ!!មានអីទេអូន

កះ បាទអ៊ុំបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំបានសំភាសន៍អ៊ុំគឺនៅថ្ងៃទី5ខែ4 ឆ្នាំ2018 ចឹងភូមិនឹងភូមិអីគេដែរអ៊ុំ?

ខះ នៅភូមិអីគេទេអ៊ុំអត់ដឹង នៅភូមិស្ទឹងជ្រៅនឹង

កះ ភូមិស្ទឹងជ្រៅ ចុះឃុំអីគេដែរ?

ខះ ឃុំផ្សារដើមមាននឹង នៅខេត្តកណ្ដាល

កះ ឃុំផ្សារដើមមាន ចុះស្រុកអីគេដែរអ៊ុំ?

ខ៖  ហ៎!!នៅស្រុកតាខ្មៅនឹង

ក៖  ចឹងនៅស្រុកតាខ្មៅណាអ៊ុំ?

ខ៖  ខ្ញុំមិនមែននៅនឹងផងនឹង

ក៖  អូ៎!!ចឹងអ៊ុំនៅណាវិញចឹងទៅអ៊ុំ?
ខ៖  ខ្ញុំនៅធនមុនហោស

ក៖  អូ៎!!នៅស្រុកតាខ្មៅនឹង ខេត្តកណ្តាល ចុះអ៊ុំមានឈ្មោះពេញនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  ចា៎!!ឈ្មោះរបស់ខ្ញុំ?

ក៖  បាទឈ្មោះពេញរបស់អ៊ុំហាសឈ្មោះអីគេ?

ខ៖  ខ្ញុំមានឈ្មោះ វី

ក៖  ចុះមានឈ្មោះអីគេដែរវីអ៊ុំ?

ខ៖  ខ្ញុំឈ្មោះពេជ្រ វី

ក៖  អូ៎!!ចឹងឈ្មោះ ពេជ្រ វី ចុះមានឈ្មោះហៅក្រៅទេអ៊ុំ?

ខ៖  អត់មានទេនឹង

ក៖  ចឹងមានឈ្មោះតែមួយនឹងទេហោសអ៊ុំ?

ខ៖  ចា៎!!មានឈ្មោះតែមួយនឹង

ក៖  ចុះកាលពីក្មេងនឹងមាននរណាហៅឈ្មោះអ៊ុំអីផ្សេងទេអ៊ុំ?

ខ៖  អត់មានទេនឹងអត់មានផងនឹង

ក៖  ចុះអ៊ុំសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖  ខ្ញុំអាយុ62ឆ្នាំហើយនឹង

ក៖  ចឹងអ៊ុំអាយុ62ឆ្នាំចឹងអ៊ុំមានដឹងថាអ៊ុំកើតនៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?
ខ៖  អើរអត់ចងចាំទេអូនអើយ អត់មានចងចាំទេ
ពីព្រោះអីបានថាអត់ចងចាំពីព្រោះកាលពីសម័យពលពតនឹងវាអស្ចារ្យហើយនឹង

កៈ អូ៎!!ចឹងឆ្នាំអ៊ុំអត់មានចងចាំដែរនឹង?

ខៈ ចា៎!!នឹងហើយ

កៈ ចឹងអ៊ុំអាយុ62ឆ្នាំមែនទេអ៊ុំ ចឹងអ៊ុំកើតនៅឆ្នាំ1956អ៊ុំ?

ខៈ ចា៎!!ចឹងហោស

កៈ ប៉ុន្តែថ្ងៃខែអ៊ុំអត់មានចងចាំទេហោសអ៊ុំ?

ខៈ អត់មានចងចាំទេ

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ ពីព្រោះអីកើតកំណើតមកវាបានធំខ្លួនមកនឹងជំនាន់

កៈ ជំនាន់លុនណុកហីអ៊ុំ?

ខៈ នៅជំនាន់លុនណុលនឹងហើយបានចូលជំនាន់ពលពតនឹងតែម្តងនឹងហាស ចឹងគ្មានបានស្គាល់ម៉ែឪ នឹងគ្មានបានស្គាល់បងប្អូនអីទាំងអស់នឹងហាស

កៈ អូ៎!!បាទប៉ុន្តែអ៊ុំពេលដែរកើតនៅអ៊ុំកើតនៅណាដែរអ៊ុំ?

ខៈ ខ្ញុំកើតអើរស្រុកកំណើតរបស់ខ្ញុំនឹងនៅខេត្តស្វាយរៀងហោស

កៈ ចឹងនៅខេត្តស្វាយរៀងហោសអ៊ុំ ចុះភូមិអីគេដែរអ៊ុំ?

ខៈ ចា៎!!នៅភូមិថ្នា

កៈ នៅឃុំអីគេដែរអ៊ុំ?

ខៈ នៅក្នុងឃុំគ្រួស

កៈ នៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀងមែនទេអ៊ុំ?

ខៈ ចា៎!!អើរ ឃុំគ្រួស ភូមិថ្នា

កៈ ចុះស្រុកវិញអ៊ុំ?

ខៈ នៅស្រុកស្វាយរៀង ខេត្តស្វាយរៀងនឹង

កៈ អូ!!ប៉ុន្តែមិនមែនស្រុកស្វាយជ្រុំទេណាអ៊ុំ?

ខៈ ចា៎!!មិនមែនទេ

កៈ អូ!!បាទ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ ខ្ញុំមានបងប្អូនចំនួន5នាក់អាពតស៊ីអស់ហើយនឹង

កៈ អើរម៉េចចឹងអ៊ុំ?

ខៈ ចុះធ្វើម៉េចបើគេយកទៅវៃចោលនឹងហាស

កៈ អូ!!ខ្ញុំលឺថាអាពតស៊ីនឹងខ្ញុំស្មានតែអាពតយកទៅធ្វើអីគេដែរ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំជាកូនទី3នឹង

កៈ ប៉ុន្តែមានស្រីប៉ុន្មានហើយនឹងប្រុសប៉ុន្មាននាក់ដែរបងប្អូនរបស់អ៊ុំ?

ខៈ មានស្រី3នាក់ នឹងប្រុស2នាក់នឹងហាស

កៈ ប៉ុន្តែចឹងមានន័យថា4នាក់ទៀតនឹងពួកគាត់បានស្លាប់អស់ហើយនឹង
ចឹងនៅតែអ៊ុំមួយទេ?

ខៈ ចា៎!!នឹងហើយ

កៈ ហេតុអីបានជាអ៊ុំរួចខ្លួនតែម្នាក់ឯងចឹងទៅអ៊ុំ?
ខៈ ខ្វរត់ខ្ញុំនៅកងនឹងខ្ញុំរត់ផងអីផង
ដើរទៅនៅជាមួយគេឯងហើយចេះតែទៅតាមគេតាមឯងនឹង
បានជារស់ខ្ញុំនឹងហើយបានមករកម៉ែឪនឹងបានជួបតែឪនឹងម្តាយគាត់បានស្លាប់ទៀត
ហើយបងប្អូនគាត់បានស្លាប់អស់ទៅ

កៈ
អូ!!បាទចុះអ៊ុំមានចងចាំបងប្អូនរបស់អ៊ុំដែរគាត់បានស្លាប់នឹងថាគាត់មានឈ្មោះអីគេខ្លះដែរ
ទៅអ៊ុំ?

ខៈ បងរបស់ខ្ញុំទី1នឹងមានឈ្មោះច្រាំង

កៈ ចុះបងទី2វិញអ៊ុំ?

ខ៖ បងទី2នឹងមានឈ្មោះប៉ាច

ក៖ ចុះទី3វិញអ៊ុំឈ្មោះអី?

ខ៖ ទី3នឹងមានឈ្មោះប៉ាង

ក៖ អ៊ុំជាកូនទៅ4នឹង?

ខ៖ ទី4នឹងមានឈ្មោះរី

ក៖ ចុះទី5វិញអ៊ុំមានឈ្មោះអីគេ?

ខ៖ ទី5នឹងមានឈ្មោះស្រីអូន

ក៖
អូ៎!!បាទចឹងអ៊ុំដូចជាអ៊ុំមានចងចាំអនុស្សាវរីយ៍អីកាលអ៊ុំនៅជាមួយបងប្អូនរបស់អ៊ុំដែរទេ?

ខ៖ អត់ចងចាំទេ

ក៖ ថាអ៊ុំធ្លាប់លេងអីជាមួយគ្នាដែរចឹង?

ខ៖ ចា៎!!ពូឈប់អាលសុំទោស

ក៖ ចុះអ៊ុំគិតថាកាលពីក្មេងអ៊ុំធ្លាប់បានលេងល្បែងឡឹកបាយឡ
រឺមួយលេងអីជាមួយបងប្អូនរបស់អ៊ុំទេ?

ខ៖ ធ្លាប់លេងតើ!!

ក៖ ដូចជាលេងអីគេខ្លះដែរអ៊ុំពេលណុងហាស?

ខ៖ លេងរាប់ពួន លេងបាយឡឹកបាយឡលេងលក់ដូរស្អីៗៗនឹងចេះតែលេងទៅនឹង

ក៖ នឹងកាលអ៊ុំនៅតូច ប៉ុន្តែអ៊ុំចូលចិត្តលេងអីគេជាមួយបងប្អូនរបស់អ៊ុំដែរទៅ?

ខ៖ លេងឡឹកឡអីចឹង លេងបិទពួន លេងដេញគ្នាអីចឹងទៅណាស់

ក៖ ចុះដូចជាចឹងបងប្អូនរបស់អ៊ុំនឹងស្លាប់អស់ហើយនឹងនៅតែអ៊ុំម្នាក់ទេណអ៊ុំ?

ខ៖ ចា៎ៗៗ!!នឹងហើយ

កៈ អូ៎!!ចុះឪពុករបស់អ៊ុំនឹងមានឈ្មោះអីគេដែរទៅអ៊ុំ?
ខៈ គាត់មានឈ្មោះអ៊ុន

កៈ ចុះគាត់មានឈ្មោះស្អីគេដែរអ៊ុនអ៊ុំ?

ខៈ គាត់មានឈ្មោះពេជ្រ អ៊ុននឹង

កៈ ប៉ុន្តែគាត់នៅរស់ដែររឺមួយក៏គាត់ស្លាប់បាត់ហើយនឹងអ៊ុំ?

ខៈ អត់ទេគាត់ស្លាប់បាត់យូរដែរហើយនឹង

កៈ ប៉ុន្តែគាត់បើនៅដល់ឥឡូវនឹងប្រហែលជាគាត់អាយុប៉ុន្មានដែរអ៊ុំមានដឹងទេ?

ខៈ អើរអត់ដឹងថាអាយុប៉ុន្មានទេនេះប៉ារបស់ខ្ញុំនឹង

កៈ ចឹងនៅឆ្នាំណាក៏អ៊ុំអត់មានដឹងថាគាត់កើតនៅឆ្នាំណាដែរណាអ៊ុំ?

ខៈ ចា៎!!អត់ដឹងទេនឹង

កៈ ចុះគាត់កើតនៅណាដែរឪពុករបស់អ៊ុំហាស?

ខៈ គាត់កើតនៅណាទេភូមិថ្នានឹងតែម្តងនឹងពីព្រោះអីម៉ែឪរបស់គាត់នៅនឹងហាស

កៈ អូ៎!!ចឹងហោសអ៊ុំ?

ខៈ ចុះម៉ែឪគាត់នៅនឹងជីដូនជីតារបស់គាត់នៅនឹងទាំងអស់នឹងហាស

កៈ បាទអ៊ុំបាទចឹងហោស?
ខៈ គាត់មិនដែរចេញពីស្រុកផងនឹងហាស

កៈ ចុះសំរាប់ម្តាយរបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ ម្តាយរបស់ខ្ញុំនឹងមានឈ្មោះសុន

កៈ ចុះគាត់មានឈ្មោះអីគេសុនដែរអ៊ុំ?

ខៈ គាត់មានឈ្មោះអ៊ុន សុន

កៈ ចឹងគាត់មានឈ្មោះអ៊ុន សុន ចុះគាត់ដល់ឥឡូវនឹងគាត់អាយុប៉ុន្មានក៏អ៊ុំអត់ដឹងដែរ?

ខ៖ អត់ដឹងទេគាត់ស្លាប់ហោស ស្លាប់តាំងខ្ញុំនៅតូចៗៗនឹងហោស

ក៖ ប៉ុន្តែដូចជាគាត់កើតនៅណាដែរអ៊ុំមានដឹងទេ?

ខ៖ គាត់កើតនៅភូមិជិតគ្នានឹងហាស

ក៖ អូ៎!!គាត់កើតនៅណុងដែរហោសអ៊ុំ?

ខ៖ ចាំ!!នៅជាមួយគ្នានឹងហាស

ក៖ ចុះកាលពីឪពុករបស់អ៊ុំនៅរស់
រឺពីដំបូងៗៗនឹងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមក្រុមគ្រួសារនឹងចិញ្ចឹមជីវិតដែរទៅអ៊ុំ?

ខ៖ គាត់អត់មានធ្វើអីទេនឹងគាត់ធ្វើតែស្រែទេ

ក៖ ចឹងមានន័យថាគាត់ធ្វើតែស្រែទេហោសអ៊ុំ?

ខ៖ ចាំ!!គាត់ធ្វើតែស្រែទេនឹង

ក៖ អូ៎!!ឪពុករបស់អ៊ុំគាត់ជាមនុស្សកាច រឺមួយក៏គាត់ស្លូតដែរអ៊ុំ?
ខ៖ គាត់អត់មានកាចអីទេគាត់នឹងហោស

ក៖ ចឹងគាត់ស្លូតហោសអ៊ុំ?

ខ៖ ចាំ!!ម៉ែឪរបស់ខ្ញុំនឹងស្លូតៗៗណាស់

ក៖ បាទ!
ចុះម្តាយរបស់អ៊ុំនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតនឹងចិញ្ចឹមក្រុមគ្រួសារដែរអ៊ុំ?

ខ៖ ម្តាយរបស់ខ្ញុំនឹងគាត់ធ្វើតែស្រែនឹង

ក៖ អូ៎!!ចឹងគាត់ធ្វើតែស្រែជាមួយឪពុករបស់អ៊ុំដែរ?

ខ៖ ចាំ!!គាត់ធ្វើតែស្រែនឹងគ្មានធ្វើអីទេ

ក៖ ម្តាយរបស់អ៊ុំគាត់កាចរឺមួយក៏គាត់ស្លូតដែរអ៊ុំ?
ខ៖ គាត់ស្លូតទេម៉ែឪរបស់ខ្ញុំនឹងហាស

កៈ
ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីកាលអ៊ុំនៅជាមួយឪពុកម្ដាយរបស់អ៊ុំកាលពីអ៊ុំនៅក្មេងៗៗ
ហាស ថាអ៊ុំធ្វើអីជាមួយគ្នាខ្លះរឺទៅស្រែអីជាមួយគ្នាចឹងហាសអ៊ុំ?
ខៈ ទៅស្រែទៅស្ទូងទៅដកអីនឹងហាស ជាមួយម៉ែឪនឹងតូចៗៗទៅ

កៈ អ៎ូ!!ចឹងណាអ៊ុំបាទ?

ខៈ ទៅស្ទូងនឹងហាសក្បាលដល់ទឹកអីហោស តូចៗៗនឹងគ្មានបងប្អូនណាធំអត់មានទេ

កៈ អ៎ូ!!បាទអ៊ុំបាទត្រូវហើយអ៊ុំបាទ?

ខៈ ធំៗៗនឹងគេមានគ្រួសារអស់ទៅនឹងគេមិននៅទេយើងតូចៗៗនឹង

កៈ គេទៅជួយការងារគាត់ចឹងទៅណាអ៊ុំ?

ខៈ ចា៎!!នឹងហើយចឹង

កៈ អ៎ូ!!បាទអ៊ុំ
ចុះឪពុករបស់អ៊ុំនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអ៊ុំដែរទេ?

ខៈ គាត់អត់ដែរបានប្រាប់អីទេនឹង

កៈ អ៎ូ!!គាត់មិនដែរបានប្រាប់អីទេណាអ៊ុំ?

ខៈ ចា៎!!អត់ដែរប្រាប់ទេ

កៈ
ចុះម្ដាយរបស់អ៊ុំវិញគាត់មានដែរប្រាប់ពីប្រវត្តិរបស់គាត់កាលពីគាត់នៅក្មេងទៅអ៊ុំដែរទេ?

ខៈ អត់អត់ដែរបានប្រាប់អីទេ

កៈ អ៎ូ!!បាទអ៊ុំបាទ ចុះយាយតាខាងម្ដាយនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ អត់ស្គាល់ទេខ្ញុំនឹងហាសគាត់ស្លាប់នឹងតាំងពីខ្ញុំកើតមកធំៗៗអស់ហើយនឹង
អត់ដែរបានឃើញមុខយាយតានឹងយ៉ាងម៉េចផងនឹង

កៈ អ៎ូ!!ចុះចឹងឈ្មោះគាត់ក៏អ៊ុំអត់ស្គាល់ដែរហោសអ៊ុំ?

ខ៖ ខ្ញុំអត់ស្គាល់ទេនឹង

ក៖ ចុះយាយតាខាងម្ដាយនឹងក៏អ៊ុំអត់ស្គាល់ដែរហោសអ៊ុំ?

ខ៖ ចា៎!!អត់ស្គាល់ទេនឹង

ក៖ បាទចុះដូចជាអ៊ុំសព្វថ្ងៃនឹងអ៊ុំនៅណាដែរអ៊ុំ?

ខ៖ ខ្ញុំនៅធនមុននឹងហោស

ក៖ នៅធនមុននឹងនៅខេត្តណាដែរទៅអ៊ុំ?

ខ៖ មិនដឹងថានៅខេត្តណាទេខ្ញុំប្ដីមកនៅនឹងហាស

ក៖ អូ៎!!អ៊ុំបានប្ដីមកនៅនឹងហោសអ៊ុំ ប៉ុន្តែអ៊ុំមកនៅនឹងយូរនៅអ៊ុំ?

ខ៖ ខ្ញុំមកនៅនឹងរកស៊ីអស់រយះពេល2ឆ្នាំហើយណាយាយ
អស់2ឆ្នាំហើយនឹងខ្ញុំមករកនៅនឹងហាស

ក៖ អូ៎!!បាទអ៊ុំបាទ ចុះអ៊ុំមានបងប្អូនរឺមួយកូនចៅណាមួយទៅរស់នៅក្រៅប្រទេសទេអ៊ុំ?

ខ៖ អត់មានទេ

ក៖ ចឹងមានតែនៅខ្មែរនឹងទេណអ៊ុំ?

ខ៖ ចា៎!!មានតែនៅនឹង

ក៖ ចុះនៅថៃ វៀតណាមអីទៅធ្វើការងារអីក៏អត់មានដែរណអ៊ុំ?

ខ៖ អត់អត់មានទេ

ក៖ អូ៎!!បាទអ៊ុំ ចុះស្វាមីរបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ សព្វថ្ងៃនឹងមានឈ្មោះនី

ក៖ ចឹងគាត់មានឈ្មោះនីណអ៊ុំ ចុះអ៊ុំមានចងចាំថាគាត់រៀបអាពាហ៍ពិពាហ៍នៅឆ្នាំណា
ខែណា ថ្ងៃណាអីដែរចឹងហាសអ៊ុំ?

ខ៖ ខ្ញុំទើបតែរៀបបានពីរឆ្នាំនឹងខ្ញុំបានប្ដីមុនមួយនឹងហាស

កៈ អូ!!ចឹងទេហោសអ៊ុំបាទ?

ខៈ នេះប្តីក្រោយទេប្តីមុនរបស់ខ្ញុំនឹងគាត់ស្លាប់បាត់ហើយនឹង

កៈ អូ!!ចឹងប្តីក្រោយនឹងទើបតែរៀបបានរយះពេល2ឆ្នាំទេណអ៊ុំ?

ខៈ ចា៎!!នឹងហើយ

កៈ អូ!!បាទ ចុះនៅពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍នឹងគិតថាអ៊ុំជាអ្នករៀបចំដោយចិត្តឯងរឺមួយក៏ឪពុកម្តាយជាអ្នករៀបចំអោយដែរ?

ខៈ មីមាបងប្អូនខាងប្តីមុនហាស

កៈ បាទមីងបាទចឹងហោស?

ខៈ គាត់ជាអ្នករៀបអោយនឹងហាស

កៈ ប៉ុន្តែប្តីរបស់មីងនឹងមានជាជំនូនអីអោយទៅមីងដែរទេ ដូចជាបណ្ណាការហាស?

ខៈ អោយដែរតើនឹងអោយនឹងដែរ

កៈ បាទមីង ចុះហេតុអីបានជាមីងបានជួបប្តីរបស់មីង ហើយបានជួបពេលណា?

ខៈ គេបងប្អូនគេអ្នកនៅនឹងចឹងគេនាំទៅហាស គេនាំទៅនឹងខ្ញុំអត់ដឹងទេ គេអ្នកនាំទៅនឹងហាស

កៈ អូ!!បាទអ៊ុំបាទចឹង?

ខៈ
ទៅស្តីទៅមីងមារបស់ខ្ញុំខាងប្តីមុននឹងគេនឹកឃើញថាគ្នាអត់បងប្អូនឪពុកម្តាយអីចឹងទៅអោយមានប្តីមានអីចឹងទៅពីព្រោះអីយើងនៅម្នាក់ឯងហាស

កៈ អូ!!ចឹងហោសអ៊ុំ ប៉ុន្តែយលងអត់ដែរស្គាល់គ្នាពីមុនទេហោសអ៊ុំ?

ខៈ អត់ដែរស្គាល់គ្នាពីមុនទេខ្ញុំមិនដែរស្គាល់ផងនឹងតែនៅនឹង ខ្ញុំមិនដែរស្គាល់ផងនឹងខ្ញុំមិនដែរមកធ្វើផងនឹង

កៈ អូ!!បាទចុះអ៊ុំមានដែរបានរៀនទេអ៊ុំ?

ខ៖ អត់ទេអត់ដែរបានរៀនទេ

ក៖ ចឹងអ៊ុំអត់ដែរបានរៀនទេហោសអ៊ុំ?

ខ៖ អត់ដែរបានរៀនទេនឹង

ក៖ ចុះភាសាផ្សេងៗដូចជាភាសាអង់គ្លេស ភាសាថៃ ភាសាវៀតណាមអីអ៊ុំមានចេះទេអ៊ុំ?

ខ៖ អត់ចេះទេនឹង

ក៖ ចឹងអ៊ុំចេះតែខ្មែរមួយទេហោសអ៊ុំ?

ខ៖ ខ្ញុំចេះតែខ្មែរមួយនឹងទេនឹង

ក៖ អូ៎!!ប៉ុន្តែកាលនៅក្មេងៗនឹងអ៊ុំមានធ្លាប់បានរៀនថ្នាក់ទីប៉ុន្មានថ្នាក់ទី1នឹងថ្នាក់ទី2ហាសអ៊ុំ?

ខ៖ កាលពីក្មេងនឹងអត់បានទេបងៗគេមានប្ដីមានប្រពន្ធនឹងគេបែកអស់នឹង ចឹងនៅសល់ខ្ញុំនឹងជាតួប្រុសបណ្ដោយនឹង

ក៖ អូ៎!!បាទអ៊ុំចឹងបាទ?

ខ៖ ចេះតួប្រុសនឹងធ្វើស្លូង ដកអីនឹងហាសវាលើតែខ្ញុំនឹងហើយនឹងប្អូនរបស់ខ្ញុំនឹងមួយ

ក៖ អូ៎!!បាទអ៊ុំបាទចឹង?

ខ៖ ចា៎!!វាចឹងឯង

ក៖ ចុះសំរាប់អ៊ុំកាលពីក្មេងនឹងអ៊ុំមានធ្លាប់មានមិត្តភក្តិដែរស្និទ្ធស្នាលដែរធំធាត់មកជាមួយគ្នាដែរទេអ៊ុំ?

ខ៖ អត់ដែរចេះមានទេលោកគ្រូអត់ទេ

ក៖ ចឹងហោសអ៊ុំបាទ?

ខ៖ មានតែបងប្អូនចឹងតែម្ដងនឹងហាសអត់ទេ

ក៖  ប៉ុន្តែកាលពីនៅក្មេងៗៗនឹងហាសជាមួយបងប្អូនជីដូនមួយ
រឺបងប្អូនអីគេខ្លះនឹងអ៊ុំធ្វើអីជាមួយគ្នាទៅ មានអនុស្សាវរីយ៍អីជាមួយគ្នាចឹងហាស?

ខ៖  គ្មានបានធ្វើអីទេលោកគ្រូ ខ្ញុំដូចជាអត់សូវមានទំនាក់ទំនងអីទេអត់មានតែម្ដងនឹង

ក៖  ចឹងអត់មានតែម្ដងនឹងហោសអ៊ុំ?

ខ៖  ធម្មតាទេស្រីនិយាយអីដូចជាការធម្មតាចឹងតែម្ដងនឹង

ក៖  អូ៎!!បាទអ៊ុំបាទ ចុះតាំងពីក្មេងនឹងរហូតមកដល់ពេលនេះហាស
អ៊ុំគិតថាអ៊ុំធ្លាប់បានធ្វើការងារអីគេខ្លះដែរនៅក្នុងជីវិតរបស់អ៊ុំហាស?

ខ៖  អត់មានដែរបានធ្វើអីទេ

ក៖  ចុះកាលពីក្មេងនឹងអ៊ុំមានធ្លាប់គិតថាអ៊ុំធ្លាប់ធ្វើស្រែ ធ្វើអីចឹងហាស?

ខ៖
ចាំ!!ធ្វើតែស្រែនឹងមកដល់ពេលដែរធំខ្លួនឡើងមកនឹងមានប្ដីមានអីនឹងក៏ធ្វើតែស្រែនឹងដែរ
នឹង

ក៖  ចឹងហោសអ៊ុំ ធ្វើស្រែរហូតណាអ៊ុំ?

ខ៖  ចាំ!!ធ្វើតែស្រែនឹងហាសគ្មានបានធ្វើអីទេ

ក៖  អូ៎!!ចុះអ៊ុំគិតថាអ៊ុំធ្លាប់ទៅធ្វើការងារនៅវាលស្រែអ៊ុំធ្លាប់ទៅណាអ៊ុំ?

ខ៖ ចាំ!!នឹងធ្លាប់

ក៖  ចុះអ៊ុំគិតថាបើកអាជីវកម្មអីនឹងអ៊ុំមានធ្លាប់បើកដែរទេលក់ដូរអីចឹងហាស?

ខ៖  អើរអត់ទេកូនអត់មានទេធ្វើតែស្រែនឹងហាស

ក៖  ចុះអ៊ុំគិតថាអ៊ុំដូចជាអ៊ុំមានធ្លាប់ចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូក ចិញ្ចឹមគោ
ចិញ្ចឹមក្របីអីនឹងអ៊ុំមានធ្លាប់ចិញ្ចឹមដែរទេ?

ខ៖  ធ្លាប់លោកគ្រូអានឹងធ្លាប់ចិញ្ចឹម

ក៖  អ៊ុំមានធ្លាប់ចិញ្ចឹមអីគេដែរទៅអ៊ុំ?

ខ៖ ចិញ្ចឹមក្របី មាន់ ទាអីនឹងចេះតែចិញ្ចឹមនឹងហាស មានជ្រូកអីចឹងទៅ

ក៖ ប៉ុន្តែចិញ្ចឹមលក្ខណះតិចតួចទេណអ៊ុំ មិនមែនចិញ្ចឹមលក្ខណះច្រើនទេណអ៊ុំ?

ខ៖ មានជ្រូកអីចឹងចិញ្ចឹមមានមេមួយ យកមេលក់កូនចឹងទៅ

ក៖ អូ៎!!បាទអ៊ុំបាទចឹង?

ខ៖ នឹងហើយធ្វើចឹងហាស

ក៖
ចុះអ៊ុំគិតថាតាំងពីក្មេងមករហូតដល់ពេលនេះនឹងជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអីគេខ្លះដែរទៅអ៊ុំ?

ខ៖ អើរដូចជាអត់មានការផ្លាស់ប្តូរអីសោះតែម្តងនឹងហាស

ក៖ អូ៎!!បាទអ៊ុំបាទចឹងហោស?

ខ៖ ជីវភាពពីមុនយ៉ាងម៉េចដល់ពេលឥឡូវនឹងមកចឹងដដែរនឹង

ក៖ បាទអ៊ុំបាទ ចុះអ៊ុំគិតថាម្ហូបអីគេដែរអ៊ុំចូលចិត្តពិសារដែរអ៊ុំ?

ខ៖
ម្ហូបអីធម្មតានឹងចេះតែចង់ហើយអានឹងគ្មានលទ្ធភាពទៅរួចមិនរួចអីនឹងអានឹងវាចឹងវាហូបតែធម្មតាចឹងទៅណាស់ចឹងតែម្តងទៅ

ក៖ ចុះដូចជាលក្ខណះថាស្លម្ជូរយួន ស្លការី ស្លកកូរអីអ៊ុំចូលចិត្តទេ?

ខ៖ ចា៎!!អានឹងវាម្តងម្កាលអីវាមិនចេះតែចូលចិត្តប៉ុន្មានទេណាស់

ក៖ អូ៎!!បាទអ៊ុំបាទ
ចុះអ៊ុំគិតថាតាំងពីក្មេងហាសល្បែងប្រជាប្រិយ៍អីគេដែរអ៊ុំចូលចិត្តលេងដែរអ៊ុំ?

ខ៖ អូ៎!!នៅនោះនឹងលេងតែទាញព្រាតនឹង បោះអង្គុញអីនឹង
ចោលឈូងអីនឹងមានតែប៉ុណ្ណឹងទេ

ក៖ អូ៎!!លេងលាក់កន្សែងអីនឹងហោសអ៊ុំ?

ខ៖ ចាំ!!នៅវាលស្រែនឹងតែម្តងនឹងហាស

ក៖ អូ!!អ៊ុំទៅលេងនៅវាលស្រែហោសអ៊ុំ?

ខ៖ លេងនៅវាលស្រែយប់ទៅចឹងទៅ

ក៖ ប៉ុន្តែអ៊ុំគិតថា?

ខ៖ ក្មេងៗនឹងចេះតែលេងនៅវាលស្រែចឹងទៅដូចថាផ្ទះចឹងវាលស្រែចឹងទៅវាស្រលះហើយនាំគ្នាលេងចឹងទៅ

ក៖ ប៉ុន្តែភាគច្រើននឹងអ៊ុំលេងលក្ខណៈថាជាមួយមិត្តភក្តិរឺយ៉ាងម៉េចដែរទៅអ៊ុំ?

ខ៖ លេងជាមួយគ្នាដូចថាផ្ទះនៅជិតៗចឹងទៅល្ងាចឡើងនឹងបបួលគ្នាលេងចឹងទៅ

ក៖ អូ!!ភាគច្រើននឹងលេងនៅពេលណាដែរអ៊ុំ?

ខ៖ ភាគច្រើននឹងលេងពេលល្ងាចៗនឹងហាស

ក៖ លេងនៅពេលជិតចូលឆ្នាំអីនឹងហោសអ៊ុំ?

ខ៖ ចាំ!!នៅរដូវចូលឆ្នាំអីចឹងទៅ

ក៖ ចុះអ៊ុំគិតថាសំរាប់អ៊ុំនឹងអ៊ុំចេះច្រៀងដែរទេ?

ខ៖ អត់ទេលោកគ្រូអើយអត់មានចេះទេ

ក៖ ចឹងអ៊ុំអត់ចេះច្រៀងទេណអ៊ុំ?

ខ៖ អត់មានចេះទេនឹង

ក៖ ប៉ុន្តែអ៊ុំចូលចិត្តស្តាប់បទចំរៀងដែរទេ?

ខ៖ ខ្ញុំចូលចិត្តស្តាប់ប៉ុន្តែអត់ចេះច្រៀងទេ

ក៖ លក្ខណៈថាបទបុរាណរឺមួយក៏បទសម័យដែរអ៊ុំ?

ខ៖ អើរបទបុរាណនឹងពិរោះជាងនឹងហាស

ក៖ អូ!!បាទបុរាណពិរោះជាងហើយអ៊ុំ?

ខ៖ ចាំៗៗ!!នឹងហើយ

ក៖ ប៉ុន្តែអ៊ុំចូលចិត្តស្តាប់ល្ខោន យីកេ អាយៃអីទេអ៊ុំ?

ខ៖ ចាំ!!ចូលចិត្តស្តាប់នឹង

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ ចូលចិត្តល្ខោនអីនឹងហាស

ក៖ ប៉ុន្តែអ៊ុំចូលចិត្តស្តាប់ធិមអីដែរតើហីអ៊ុំ?

ខ៖ មានអីលោកគ្រូដល់ពេលដែរយើងចាស់ខ្លួនទៅនឹងចង់ធិមចង់អារ្យចឹងហាស

ក៖ បាទអ៊ុំបាទ
ចុះមាននរណាគេនៅក្នុងក្រុមគ្រួសាររបស់អ៊ុំនឹងចេះលេងឧបករណ៍ភ្លេងដែរទេអ៊ុំ?

ខ៖ អត់ទេអត់មានទេ

ក៖ ភ្លេងខ្មែរ ភ្លេងសៀមអីនឹងអត់ដែរ?

ខ៖ អត់មានទេអត់ទាំងអស់នឹងហាស

ក៖
អូ៎!!បាទចុះផ្ទះរបស់អ៊ុំនឹងមានលក្ខណះបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាស ថាផ្ទះកាលពីក្មេងនឹងផ្ទះយ៉ាងម៉េចហើយឥឡូវនឹងផ្ទះយ៉ាងម៉េចចឹងហាស?

ខ៖ ផ្ទះនឹងធម្មតានឹងស្លឹកយើងនឹង
គ្រាន់តែថាវាមិនកន្ទ្រប់អីទេវាលើកឈើយើងធម្មតាអីចឹងទៅ

ក៖ អូ៎!!ដូចជាអានឹងកាលពីនៅក្មេងមែនទេអ៊ុំរឺមួយក៏នៅប៉ុណ្ណឹងហើយអ៊ុំ?

ខ៖ ចាំ!!កាលពីក្មេងនឹងឪម៉ែរបស់ខ្ញុំនឹងច្រើនតែធ្វើផ្ទះពីដើមនឹងផ្ទះយើងពីដើមហាស មានសសរមូលៗអីចឹងទៅប៉ុន្តែគ្រាន់តែថាផ្ទះឈើនឹងមិនបានផ្ទះអីទេណាស់

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ ផ្ទះឈើយើងធម្មតាអីចឹងហាស

កៈ ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងនរណាគេជាអ្នកសាងសង់ដែរអ៊ុំ?

ខៈ ឪពុកម្ដាយរបស់ខ្ញុំនឹងហាស

កៈ អូ!!ឪពុករបស់អ៊ុំចេះធ្វើផ្ទះហោសអ៊ុំ?

ខៈ ជួលគេអត់ចេះទេគាត់ជួលគេចឹងហាស

កៈ អោយលុយគេដើម្បីអោយគេនឹងជួយធ្វើណាអ៊ុំ?

ខៈ ចាំ!!នឹងហើយជួលគេនឹង

កៈ ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងគេធ្វើប្រើឧបករណ៍អីអ៊ុំមានដឹងទេ
មានសំភារះអីចឹងហាសអ៊ុំ?

ខៈ ខ្ញុំឃើញគេស្អីគេទេមានរណា
មានស្អីៗគេគ្រប់មុខនឹងហាសជាងគេខ្ញុំមិនសូវដឹងដែរនឹង

កៈ នឹងហើយមានរណា មានញញួរអីចឹងហោសអ៊ុំ មានដែកកាប់ មានដែកគាស់?

ខៈ ចាំ!!នឹងហើយ

កៈ ចុះអ៊ុំគិតថាជំនាញអីគេដែរអ៊ុំចេះស្ទាត់ជំនាញដែរហោសអ៊ុំ?

ខៈ ខ្ញុំគ្មានចេះស្ទាត់ជំនាញអីគេទេ

កៈ ប៉ុន្តែអ៊ុំចេះធ្វើស្រែមែនទេអ៊ុំ?

ខៈ ខ្ញុំចេះធ្វើស្រែតែមួយមុខគត់នឹងហាស

កៈ អូ!!បាទអ៊ុំ
ចុះលក្ខណះថាម្ដាយឪពុករបស់អ៊ុំនឹងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅអ៊ុំដែរទេ?

ខៈ អត់មានជំនាញអីទេ

កៈ ដូចជាលក្ខណះធ្វើផ្ដៅ វេញល្ហើ កូរស្ករ?

ខៈ អត់ទេនៅស្រុកនេះអត់មានទេនឹង

កៈ ចឹងអត់ទេណាអ៊ុំណា?

ខ៖ ចា៎!!អត់មានទេនឹង

ក៖
អ៊ុំអាចប្រាប់ពីពេលលំបាកតាំងពីក្មេងរហូតមកដល់ពេលនេះបានទេអ៊ុំពីការលំបាកអ៊ុំធ្លាប់ជួប ការលំបាកអីគេខ្លះដែរចឹងហាសអ៊ុំ?

ខ៖ ហ៎ា!!លំបាកនឹងលំបាកអស់ទាស់ហើយនឹងលោកគ្រូ
ណាមួយជួបម៉ែឪរយះកាលបន្តិចទៀត
ធំខ្លួនឡើងនឹងធំបច្ចុប្បន្នមកធំខ្លួនមកព្រាត់ប្រាស់ម៉ែឪអស់ហើយនឹង

ក៖ អ្ហ៎!!ដូចជាថគាត់ទៅណាវិញអ៊ុំ?

ខ៖ ដូចថាធំឡើងនឹងវាមិនត្រូវជំនាន់គេនឹង

ក៖ បាទអ៊ុំបាទនឹង?

ខ៖ ចា៎!!យើងនឹងមិនព្រាត់ប្រាស់ម៉ែឪនឹង ហើយយើងនៅតែម្នាក់ឯងចឹងទៅ
គេយកយើងទៅធ្វើកងនារី អីចឹងទៅណាស់យកទៅដាក់កុមារអីចឹងទៅណាស់

ក៖ ប៉ុន្តែកាលណុងអ៊ុំនៅអាយុប៉ុន្មានដែរទៅអ៊ុំ?

ខ៖ ខ្ញុំមិនដឹងថាអាយុប៉ុន្មានទេលោកគ្រូអើយ

ក៖ ប៉ុន្តែពេលណុងអ៊ុំធំហើយមែនទេ?

ខ៖ នឹងកាលណុងធំគេយកទៅដាក់ចឹងទៅ

ក៖ ប៉ុន្តែនៅកងនារីហោសអ៊ុំ?

ខ៖ ចា៎!!នឹងហើយវេទនាណាស់រត់មករកម៉ែឪនឹង
វេទនាណាស់រត់ប៉ុន្មានដងហើយនឹងគេចាប់បានប៉ុន្មានដងហើយនឹង

ក៖ អ្ហ៎!!គេចាប់គេមិនអោយមកហោស?

ខ៖ ចា៎!!គេចាប់យើង

ក៖ ចុះមកពីហេតុអីដែរអ៊ុំ?

ខ៖  អត់ដឹងទេមិនដឹងថាជាស្អីគេគេមិនអោយយើងទៅជួបម៉ែឪផងនឹង ខ្ញុំរត់កាលណុងពេលបច្ចុប្បន្ននឹង យើងមិនមានប្រឡាយគេជីក

ក៖  បាទអ៊ុំបាទនឹង?

ខ៖  ខ្ញុំបានរត់តាមប្រឡាយនឹងគេបានឃើញគេបាត់ខ្ញុំនឹងគេរត់រក គេតាមឃើញខ្ញុំមកនៅប្រឡាយចេះ តែលូនៗមកមកជួបម៉ែឪនឹង

ក៖  ចឹងអត់បានជួបដដែលនឹង

ខ៖  ហើយមិនបានជួបដដែលនឹងហាស

ក៖  ប៉ុន្តែពេលណុងអ៊ុំនៅណាដែរអ៊ុំគេអោយនៅណា?

ខ៖  ខ្ញុំនៅខេត្តស្វាយរៀងនឹងកាលណុង

ក៖  អ៎ូ!!ប៉ុន្តែគេអោយអ៊ុំធ្វើអីគេដែរជាកងនារីហាស?

ខ៖  គេអោយជីកប្រឡាយជីកស្អីៗៗរួមគ្នានឹងគ្រប់មុខនឹងគេប្រើអោយយើង

ក៖  ប៉ុន្តែនៅលក្ខណះជាគ្នាច្រើនមែនទេអ៊ុំ?

ខ៖  មានគ្នាច្រើនណាហ្វបមិនឆ្អែតណាអីទេគ្រប់មុខនឹងហាស

ក៖  អ៎ូ!!បាទ ចុះពេលណុងបងប្អូនរបស់អ៊ុំនមឹងគេអោយទៅណាដែរទៅ?

ខ៖

បងប្អូនរបស់ខ្ញុំនឹងគេមានប្តីមានស្រីតាំងពីមុននឹងហោសហើយគេបែកទៅនៅផ្សេងៗៗឆ្ងាយៗៗ ខ្លះមីមួយនឹងមកនៅគៀនស្វាយនេះអីៗៗនឹងហាស

ក៖  អ៎ូ!!បាទអ៊ុំបាទ?

ខ៖  នៅបែកគ្នាខ្ទែកគ្នាអស់ហើយនឹងហាស

ក៖  បាទគាត់បានស្លាប់នៅក្នុងជំនាន់ពលពតចឹងទៅ?

ខ៖  ចា៎!!មិនដឹងថាស្លាប់មិនដឹងថារស់ទេនឹង

ក៖  អ៎ូ!!ចឹងមានន័យថាបែកគ្នានឹងមិនដែរឃើញគ្នាផងហោសអ៊ុំ?

ខ៖ ចាំ!!មិនដែរបានឃើញគ្នាផងនឹង

ក៖ បាទអ៊ុំចឹងរហូតដល់ចឹងមានន័យថាអ៊ុំនៅតែកន្លែងណុងមួយទេ អ៊ុំនៅតែគៀនស្វាយនឹងមួយកន្លែងទេគ្មានផ្លាស់ទៅណាផ្សេងទៀតណាហីអ៊ុំ?

ខ៖ អត់ទេអត់មានផងនឹង

ក៖ គេអោយនៅតែធ្វើនៅណុង?

ខ៖ ចាំ!!នឹងហើយ

ក៖ ប៉ុន្តែគេអោយអ៊ុំធ្វើអីគេដែរធ្វើស្រែមែនទេ?

ខ៖ អត់មានធ្វើស្រែទេកាលពីជំនាន់ពលពតនឹងគេអោយជីកប្រឡាយនឹងហាសជីកអីចឹង នឹងដើរលើកប្រព័ន្ធភ្លឺនឹងហាស

ក៖ អានឹងក្រុមរបស់អ៊ុំណាអ៊ុំ?

ខ៖ នឹងក្រុមមួយកំណាត្ចមួយកងៗនឹងហាសមិនដឹងថាប៉ុន្មានក្រុមប៉ុន្មានមេទៅ

ក៖ អូ៎!!ចឹងមានន័យថាច្រើនហោសអ៊ុំ?

ខ៖ មានច្រើនណាស់ គេចាប់យកទៅពេលធំខ្លួនឡើងនឹងគេនៅចឹងទៅដល់ពេលគេនៅចឹងទៅណាស់ ខ្លះក៏ឈឺស៊ីផ្អែត ហើយមានឈឺស្លាប់ក៏មានដែរ

ក៖ អូ៎!!ស្លាប់ដោយសារតែអត់អាហារនឹងហោសអ៊ុំ?

ខ៖ ចាំ!!ហើយគេប្រើយើងនឹងគ្មានស្គាល់ម៉ោងស្គាល់ពេលទេនឹងហាស មេឃក្តៅខ្លាំងនឹងប្រៀបធៀបដូច ថាខែដែតអីចឹងហាសណាស់

ក៖ អូ៎!!ខែក្តៅខ្លាំងហោសអ៊ុំ?

ខ៖ អើរមិនបាច់ទេមិនបាច់ប្រាប់ទេ

ក៖ អូ៎!!ចឹងរហូតចឹងមានន័យថាអ៊ុំនៅរហូត3ឆ្នាំនឹង8ខែនឹងតែម្តងហោសអ៊ុំ?

ខ៖ ចា៎!!នៅទាល់តែបែកនឹងចុះរត់ទៅណារួច
ដល់ពេលដែរបែកនឹងខ្ញុំបានរត់មកតែម្នាក់ឯងនឹង
ពេលមកដល់ជួបមានតែឪមួយនឹងនៅតែលគោលនឹងហាស

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ បាននៅតែជាមួយឪពុកនឹងមួយចឹងទៅ

ក៖ ចុះធ្វើម៉េចបានយើងរត់មកជួបគាត់បានដោយសារតែពេលណុង?

ខ៖ ខ្ញុំចេះតែ

ក៖ ពេលណុងមិនទាន់មានប្រព័ន្ធទូរស័ព្ទអីផងនឹងហោសអ៊ុំ?

ខ៖
អត់ខ្ញុំចេះតែដើរមករកកន្លែងដែរដូចថាឪពុកម្ដាយធ្លាប់មកនៅកន្លែងណាយើងមកកន្លែង
នឹងចឹងហាស ចឹងខ្ញុំមកសួរគេសួរឯងចឹងទៅ
ហើយខ្ញុំចេះតែសួរថាមានឃើញប៉ារបស់ខ្ញុំអត់
ហើយដល់ពេលចឹងគេថាប៉ាហែងនៅនេះនៅនោះចឹងយើងចេះតែទៅទៀតចឹងទៅណាស់

ក៖ យើងទៅរកទាល់តែឃើញចឹងទៅណាអ៊ុំ?

ខ៖ ចា៎!!យើងរកទាល់តែឃើញនឹងហាស

ក៖ ចឹងមានន័យថាឪពុករបស់អ៊ុំនឹងគាត់ទើបតែស្លាប់ថ្មីៗៗនឹងដែររឺយ៉ាងម៉េចដែរអ៊ុំ?

ខ៖ គាត់ស្លាប់ពេលដែរបែកហើយនឹងហាស

ក៖ ចឹងពេលដែរបែកហើយនឹងហោសអ៊ុំ?

ខ៖ ចា៎!!នឹងហើយ

ក៖ ចុះគាត់កើតអីអ៊ុំគាត់ឈឺរឺយ៉ាងម៉េចដែរទៅ?

ខ៖ គាត់ឈឺគាត់ចាស់ហើយនឹងហាស ណាគាត់ហូបមិនឆ្អែតនឹងគ្រូអើយ

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ វេទនាចង់ស្លាប់ហើយនឹង

ក៖ ចុះនៅពេលដែរបែកហើយនឹងពេលណុងអ៊ុំមានគ្រួសារនៅអ៊ុំ?

ខ៖ ខ្ញុំនៅទេមិនទាន់មានទេ

ក៖ រហូតមកដល់ឆ្នាំណាបានអ៊ុំចាប់ផ្ដើមមានគ្រួសារចឹងទៅ?

ខ៖
អូ៎!!យូរណាស់បែកហើយនឹងយើងមកអ្នកភ្នំពេញនឹងគេស្រុកស្រួលវិញហើយនឹងបានខ្ញុំមាននឹង

ក៖ អូ៎!!បាទអ៊ុំ ចុះនៅពេលដែរបែកហើយនឹងអ៊ុំធ្វើអីគេដែរអ៊ុំ
ពេលណុងនឹងមានការលំបាកម្ដងទៀតមែនទេអ៊ុំ?

ខ៖
ពេលដែរបែកហើយចឹងទៅយើងមានធ្វើអីទេយើងនៅណុងនៅខេត្តស្វាយរៀងចឹងទៅធ្វើតែស្រែ នឹងគេចែកដីអោយចឹងទៅធ្វើចឹងទៅ

ក៖ អូ៎!!ចឹងមានន័យថាចឹងអ៊ុំនៅតែពីរនាក់ឪពុករបស់អ៊ុំទេ?

ខ៖ ខ្ញុំនៅតែពីរនាក់នឹងហាស

ក៖ អូ៎!!បាទរហូតដល់ឆ្នាំណាដែរបានអ៊ុំគិតថាអ៊ុំមានគ្រួសារហាសអ៊ុំ?

ខ៖ ដល់ពេលដែរឪពុករបស់ខ្ញុំនឹងគាត់ស្លាប់បាត់ទៅ
ស្លាប់ចឹងទៅមីងមារបស់ខ្ញុំគេចូលស្ដីចឹងទៅ មីងមារបស់ខ្ញុំក៏រៀបចំអោយចឹងទៅណាស់

ក៖ អូ៎!!ចឹងមានន័យថាឪពុករបស់អ៊ុំស្លាប់នឹងអ៊ុំទៅនៅជាមួយមីងមាមែនទេអ៊ុំ?

ខ៖ ចា៎!!នឹងហើយ

ក៖ ប៉ុន្តែនៅខេត្តស្វាយរៀងនឹង

ខ៖ ចា៎!!នៅជាមួយមីងមានឹងយើងរស់នៅជាមួយគាត់នឹងទៅធ្វើស្រែធ្វើអីស៊ីចឹងទៅ
ហើយដល់ពេលចឹងគេមកសួរនាំអីចឹងទៅគាត់អ្នកទុកដាក់អីអោយចឹងទៅណាស់

ក៖ អូ៎!!បាទអ៊ុំ ចុះអ៊ុំគិតថាអ៊ុំឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរទៅអ៊ុំ?

ខ៖ អូ!!ពិបាកណាស់គ្រូអើយសួររឿងនឹងពិបាកណាស់

ក៖ ដូចជាអ៊ុំជំនះឧបសគ្គវាដោយរបៀបម៉េចដែរដើម្បីអ៊ុំអាចឈ្នះវាចឹងហាសអ៊ុំ?

ខ៖ ចេះតែតស៊ូទៅគ្រូមិនដឹងថាយើងស្លាប់យើងរស់ទេយើងតស៊ូនឹងហាស
ដូចថាយើងរស់ក៏រស់ទៅ យើងស្លាប់ក៏ស្លាប់ទៅនឹង

ក៖ យើងចេះតែទៅមុខចឹងទៅណាអ៊ុំ?

ខ៖ ចាំ!!ចេះតែទៅហើយដូចថាកន្លែងនឹងមានបន្លាច្រើនណាស់
ចុះបើយើងមិនទៅចឹងយើងមិនដឹងថាធ្វើម៉េច
បើមិនទៅចឹងម៉េចបានដឹងថាជួបម៉ែឪនឹងបងប្អូនចឹង
ចេះតែតស៊ូចឹងទៅគេចាប់បាននឹងស្លាប់ត្រង់ណានៅត្រង់នឹងទៅ អានឹងវាចឹងហាសគ្រូ

ក៖ អូ!!បាទអ៊ុំបាទ?

ខ៖ នឹងមានតែចឹង

ក៖ ចុះសំរាប់ពេលណាដែរអ៊ុំគិតថាសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់អ៊ុំដែរ?

ខ៖
អូ!!ទើបតែមកបានធូរពេលបច្ចុប្បន្ននៅពេលស្រុកទេសយើងបានស្រួលបួលនឹងហាសគ្រូ

ក៖ ពេលណុងអ៊ុំគិតថាអ៊ុំរៀងបានធូរស្រាលជាងមុនហើយណាអ៊ុំ?

ខ៖ រៀងធូរប៉ុន្តែកុំអោយគេរំលឹងរឿងចាស់
តែរំលឹករឿងចាស់នឹងនៅក្នុងឆាកជីវិតរបស់ខ្ញុំហាស

ក៖ អ៊ុំឈឺចាប់ណាអ៊ុំ?
ខ៖
ចាស់!!វាកំសត់ណាមួយវាបានជួបបងប្អូនធូរដូចគេចឹងទៅមកហាសចឹងវាបានជួបឪពុកម្តាយចឹងទៅ ចឹងវាមិនបានជួបហាស

ក៖ បាទអ៊ុំបាទនឹង?

ខ៖ ដល់ពេលចឹងតែលតោលហាស
ម៉េចគេហៅតែលតោដូចនឹងគេហៅប្រៀបធៀបដូចទឹកមានចកនៅ
កណ្ដាលទន្លេចឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ ងាកទៅណាលឹងលើមៗចឹងហាសល្មមនឹងតោងច្រាំងបាននឹងហាស

ក៖ ទាល់ឥឡូវនឹងហោសអ៊ុំ?

ខ៖ ចា៎!!នឹងហើយ

ក៖ ចុះអ៊ុំគិតថាកូនចៅរបស់អ៊ុំនឹងមានគ្រួសាររស់នៅអ៊ុំ?

ខ៖ ខ្ញុំគ្មានកូនចៅណាខ្ញុំអត់មានកូនផងនឹង

ក៖ ចឹងអ៊ុំអត់មានកូនទេហោសអ៊ុំ?

ខ៖ ចា៎!!អត់មានទេ

ក៖ ទាល់តែឥឡូវនឹងក៏អត់មានដែរណាអ៊ុំ?

ខ៖ អត់មានទេ

ក៖ អូ៎!!ចឹងដូចជា ចឹងនៅពេលដែរអ៊ុំបានរៀបអាពាហ៍ពិពាហ៍នឹងក៏អ៊ុំសប្បាយដែរណាអ៊ុំ?

ខ៖ ចា៎!!នឹងហើយ

ក៖ អូ៎!!បាទអ៊ុំ ចុះអ៊ុំធ្លាប់មានក្ដីស្រម៉ៃទេថាកាលពីក្មេងនឹងអ៊ុំធ្លាប់ចង់ធ្វើអីដែរទេ?

ខ៖ ស្រម៉ៃនឹងវាស្រម៉ៃហើយគ្រូប៉ុន្តែយើងវាទាល់ក្រ

ក៖ ប៉ុន្តែអ៊ុំគិតថាពេលណុងអ៊ុំចង់ធ្វើអីគេដែរទៅអ៊ុំ?

ខ៖ចេះតែចង់ធ្វើមុខជំនាញអីចង់ធ្វើការងារអី
ដូចថារកស៊ីមុខជំនាញអីចឹងនឹងគេនឹងឯងចឹងទៅណាស់

ក៖ បាទអ៊ុំបាទ?

ខ៖ ណាគ្រូប៉ុន្តែយើងលទ្ធភាពយើងវាទៅមិនរួចនឹងហាស

កៈ  យើងទៅអត់ដល់ណាអ៊ុំ?

ខៈ  ចា៎!!នឹងហើយ

កៈ  ប៉ុន្តែពេលណុងអ៊ុំចង់ធ្វើអីគេដែរទៅ?

ខៈ  ខ្ញុំចង់ដូចថារកស៊ីលក់ដូរចិញ្ចឹមជីវិតនៅផ្ទះចឹងទៅណាស់
ចាដល់ពេលចឹងអត់អាចឈោងវាមិនដល់ ចឹងទៅណាស់

កៈ  បាទអ៊ុំបាទ
ចុះបើសិនជាចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗៗនឹងតើអ៊ុំចង់ផ្ដែផ្ដាំអីទៅ
ពួកគាត់ដែរទៅអ៊ុំ?

ខៈ  មិនដឹងផ្ដាំថាម៉េចទេលោកគ្រូ
បើថាស្រុកទេសគេថាអោយល្អនឹងវាល្អជាងយើងពីមុនទៀតណោះនឹង

កៈ
បាទអ៊ុំប៉ុន្តែបើសិនជាចង់អោយអ៊ុំអោយក្មេងៗៗជំនាន់ក្រោយៗៗអោយពួកគាត់ខំប្រឹងរៀន
នឹង អោយខំតស៊ូអីចឹងហាស?

ខៈ  ចា៎!!នឹង

កៈ  អ្វីដែរអ៊ុំចង់ផ្ដែផ្ដាំអីគេបានខ្លះៗៗដែរទេ?

ខៈ  ឥឡូវនឹងគ្រាន់តែថាឥឡូវនឹងក្មេងៗៗជំនាន់ក្រោយៗៗនឹងវាខំតស៊ូដើម្បី
ធ្វើការងារបានធ្វើការតស៊ូ បានធ្វើការងារនឹងគេចឹងទៅ
កុំអោយដូចជំនាន់អ៊ុំពីមុនចឹងទៅណាស់

កៈ  បាទអ៊ុំបាទ?

ខៈ  ចា៎!!ហើយតស៊ូអោយបានក្លាហានឡើងនឹងហាស

កៈ  បាទអ៊ុំបាទ?

ខៈ  ហើយនឹងអោយជៀសផុតពីគ្រឿងញៀននឹងកុំអោយ

កៈ  កុំអោយញៀនណាអ៊ុំ?

ខ៖
ចាំ!!កុំអោយយកមកបៀតបៀនជាប់ខ្លួននឹងកុំយកចិត្តទុកដាក់ខំតស៊ូឡើងអោយល្អកុំអោយមានអី អោយយើងខំរកអនាគត់យើងបានភ្លឺស្វាងហាសណាស់

ក៖ បាទអ៊ុំបាទ ចុះចឹងមានអីដែរអ៊ុំចង់ផ្ដែផ្ដាំផ្សេងទៀតទេអ៊ុំ?

ខ៖ អត់មានទេ

ក៖
បាទចឹងជាចុងក្រោយខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំពិភាក្សាដែរទាក់ទងពីប្រវត្តិរបស់អ៊ុំ
ហើយខ្ញុំនឹងដាក់ការសំភាសន៍នឹងទៅក្នុងវេបសាយរបស់សាលា
ដើម្បីតំកល់ទុកអោយកូនចៅរបស់អ៊ុំ
នឹងកូនក្មួយក្រោយៗអោយពួកគាត់បានស្គាល់នឹងបានដឹងពីប្រវត្តិរបស់អ៊ុំចឹងហាសអ៊ុំ?

ខ៖ ចាំៗ!!នឹងហើយ

ក៖ បាទចឹងអរគុណច្រើនអ៊ុំ៕៕៕